ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៧
ចុះថ្ងៃទី១៥-១១-២០០០
សាលដីកាលេខ៖ ១២
ចុះថ្ងៃទី០៧-០៣-២០០១

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែមីនាឆ្នាំ ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅៈ

១-ឯកឧត្តម... ប្រធាន
២-លោក.... ចៅក្រម
៣-លោក.... ចៅក្រមរបាយការណ៍
៤-លោក... ចៅក្រម
៥-លោក... ចៅក្រម

លោក... ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក..... ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខគ្មានលេខ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០០០ របស់ឈ្មោះ **ណត** និង **ណណ** ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ១៦៧ ចុះថ្ងៃទី១៥-១១-២០០០ របស់តុលាការកំពូល។

១-ជនជាប់ចោទ ឈ្មោះ **ណណ** ម្ចាស់បណ្ដឹងសាទុក្ខ ភេទ ប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃភូមិ ឃុំ រមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ... ម្ដាយឈ្មោះ...ប្រពន្ធឈ្មោះ...ទោសពីមុនគ្មាន ។នៅក្នុងឃុំ។

២-ជនជាប់ចោទ ឈ្មោះ **ណណ** ភេទ ប្រុស អាយុ៣៧ ឆ្នាំ ម្ចាស់បណ្ដឹងសាទុក្ខ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃភូមិកណ្ដាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ... ម្ដាយឈ្មោះ... ប្រពន្ធឈ្មោះ...ទោសពីមុខគ្មាន នៅក្នុងឃុំ។

-ត្រូវចោទពីបទមនុស្សឃាតគិតទុកជាមុន

-មេធាវី អ្នកស្រី...

៣-ជនជាប់ចោទ ឈ្មោះ **ណណ** ភេទ ប្រុសអាយុ២៨ ឆ្នាំ ជាតិខ្មែរ កើតនិងទីលំនៅមុន ពេលចាប់ខ្លួនភូមិកណ្ដាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។ឪពុកឈ្មោះ...ម្ដាយឈ្មោះ...នៅលីវ ទោសពីមុនគ្មានគេចខ្លួន។

- ត្រូវចោទពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិកណ្ដាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣-០១-៩៨ បទល្មើសព្រហ្មទណ្ឌ ដែលចែងឱ្យផ្ដន្ទាទោស តាមមាតា៣៤ និង៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនរងគ្រោះឈ្មោះ **វ** គ្មានសាវតាជាតិ (ស្លាប់)

-មេធាវី គ្មាន

-តាមបណ្ដឹងសាទុក្ខគ្មានលេខ ចុះថ្ងៃទី២៨-០៥-២០០០ របស់ឈ្មោះ **ណណ** និង **ណណ** ដែលប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០២ ចុះថ្ងៃទី១៩-០៤-០០ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល។

-តាមអង្គហេតុ កាលពីថ្ងៃទី០៣-០១-៩៨ ឈ្មោះ**ណណ,ណណ,ណណ** និងឈ្មោះ **មប** រៀបគម្រោងដើម្បីសម្លាប់មនុស្សឈ្មោះ **រ** យកម៉ូតូមួយគ្រឿង។ អ្នកទាំង៤បានត្រៀមស្នូរចាក់កណ្ដុរ កាំបិតខ្វែវ កាំបិតចិតបន្លែ។ លុះពេលល្ងាច អ្នកទាំង៤បបួលជនរងគ្រោះឈ្មោះ **រ** ផឹកស្រាពេលស្រវឹង ក៏បបួលជនរងគ្រោះទៅចាក់កណ្ដុរនៅបឹងស្វាយរមាស ស្រាប់តែឈ្មោះទាំង៤ ព្រួតគ្នាវាយចាក់ជនរងគ្រោះបណ្ដាលឱ្យស្លាប់ ហើយដោះយកសម្ភារៈមាននាឡិកា,ចិញ្ចៀន ខ្សែករ ហើយក៏អូសសាកសពដាក់ចូលក្នុងបឹងក្រោមកំប្លោក ឯម៉ូតូជនរងគ្រោះ ដែលទុកនៅផ្ទះ **ណណ** នោះត្រូវឈ្មោះ **ណណ** និង **ម** ជិះយកទៅបាត់ទៅ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការខេត្តកណ្ដាលសម្រេច

១-ចោទប្រកាន់លើឈ្មោះ **ណណ** អាយុ៤៧ ឆ្នាំ ឃុំខ្លួនឈ្មោះ **ណណ** អាយុ៣៧ ឆ្នាំ ឃុំខ្លួនភូមិកណ្ដាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឈ្មោះ**ណណ** អាយុ២៨ ឆ្នាំ (គេចខ្លួន)។

ពីបទ: ប្លន់ និងសម្លាប់មនុស្ស នៅខេត្តកណ្ដាល

២-បង្គង់បណ្ដឹងអាជ្ញាលើឈ្មោះ **ម** អាយុ៣៧ឆ្នាំ (គេចខ្លួន)។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២២ ចុះថ្ងៃទី១៦-៦-៩៨ របស់តុលាការខេត្តកណ្ដាល ដែលបានសម្រេចដូចតទៅ:

១-ផ្ដន្ទាទោស៖

-ឈ្មោះ **ណណ** ភេទ ប្រុសអាយុ៤៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២៦-០១-៩៨។

-ឈ្មោះ **ណណ** ភេទ ប្រុសអាយុ៣៧ ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២៦-០១-៩៨។

-ឈ្មោះ**ណាណា** ភេទប្រុស អាយុ២៨ ឆ្នាំ ដាក់ពន្ធនាគារ  កំណត់១៨ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទមនុស្សឃាតគិតទុកជាមុន  កាលពីថ្ងៃទី០៣-០១-៩៨នៅភូមិកណ្តាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-វត្ថុតាងមានរបងឫស្សី១ប្រវែង១,៧០ម  កូនកាំបិតចិតបន្លែ១ខោអាវមួយចំនួន ត្រូវរឹបអូសបំផ្លាញចោល។

៣-ទុកសិទ្ធិឱ្យគ្រួសារជនរងគ្រោះ  ប្តឹងទាមទារសំណងជំងឺចិត្តពីជនជាប់ចោទទាំងពីរនាក់នេះបាន។

៤-សាលក្រមនេះ  ជំនុំជម្រះ  និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **ណាណា,ណាណា** កំបាំងមុខជនជាប់ចោទ ឈ្មោះ **ណាណា** និងគ្រួសារជនរងគ្រោះ។ បើកផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង និងប្តឹងឧទ្ធរណ៍ រយៈពេល២ខែ គិតពីថ្ងៃផុតកំណត់ប្តឹងទាស់ចំពោះ ឈ្មោះ **ណាណា** និងគ្រួសារជនរងគ្រោះ។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-៧-៩៨ របស់ឈ្មោះ **ណាណា, ណាណា** ដែលប្តឹងពីសាលក្រមព្រហ្មទណ្ឌលេខ២២ចុះថ្ងៃទី១៦-៦-៩៨ របស់តុលាការខេត្តកណ្តាល លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន  របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ សុំឱ្យតុលាការសម្រេចតែម្តង ព្រោះការសួរដេញដោល គឺបានសួររួចហើយ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០០កន្លងមក។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០២  ចុះថ្ងៃទី១៩-៤-០០របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច

-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-៧-៩៨ របស់ឈ្មោះ **ណណ,ណណ** ទុកជាត្រឹមត្រូវតាមទម្រង់តែបដិសេធចោល ដោយទាស់ខុសនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២២(ព) ចុះថ្ងៃទី១៦-៦-៩៨ របស់តុលាការ ខេត្តកណ្តាល ទុកជាបាន ការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខមេធាវី ...កំបាំងមុខជនជាប់ចោទបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខគ្មានលេខ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២000 របស់ឈ្មោះ **ណណ និង ណណ** ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-00 របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញលិខិតបង្គាប់ឱ្យធ្វើសារណា ចុះថ្ងៃទី២៨-១១-00 របស់តុលាការកំពូលបង្គាប់ឱ្យឈ្មោះ **ណណ, ណណ** ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើសារណាការពារផលប្រយោជន៍ របស់ខ្លួនហើយឈ្មោះនេះបានទទួលនៅថ្ងៃទី២៨-១១-00 រួចហើយ ប៉ុន្តែមិនបានធ្វើសារណាតាមកំណត់ច្បាប់ទេ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ **ណណ និង ណណ** ពីបទប្លន់និងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិកណ្តាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី៣-១-៩៨ ឡើយ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ណណ** នាពេលសវនាការថាបានជាខ្លួនប្តឹងសាទុក្ខមិនសុខចិត្តពីសាលដីកាសាលាឧទ្ធរណ៍ ព្រោះថារឿងហេតុទាំងអស់ដែលកើតឡើងកាលពី ថ្ងៃទី០៣-១-៩៨ នោះខ្លួនពុំបាន ដឹងអ្វីឡើយគឺ

ខ្លួននៅផ្ទះមើលកូន មិនដើរទៅណាទេ មានអ្នកជិតខាង នៅក្បែរផ្ទះបានដឹងឮដែរ សូមតុលាការកំពូលរកយុត្តិធម៌ឱ្យខ្លួនផង។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ណណ នាពេលសវនាការថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើមនុស្សឃាត នៅក្នុងរឿងនោះទេ ឯអ្នកស្លាប់ក៏ខ្លួនមិនដែលស្គាល់ ហើយឈ្មោះ **ម** នោះក៏ខ្លួនរិតតែមិនស្គាល់ទៅទៀត ចំពោះឈ្មោះ **ណណ** ជាប្អូននោះពុំដែលទំនាក់ទំនងជាមួយខ្លួនដែរ។ នៅពេលចាប់ខ្លួន គឺខ្លួននៅលើផ្ទះថែរក្សាប្រពន្ធឆ្លងទន្លេឯផ្ទះ **ណណ** ក៏នៅឆ្ងាយពីផ្ទះខ្លួនដែរ សូមតុលាការរកយុត្តិធម៌ផង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី... ការពារឱ្យជនជាប់ចោទឈ្មោះ**ណណ និង ណណ** នាពេលសវនាការថា៖ តាមនីតិវិធីនៃរឿងព្រហ្មទណ្ឌការចាប់ខ្លួនឃុំខ្លួនគឺជាការប្រព្រឹត្ត និងកំពុងប្រព្រឹត្តជាក់ស្តែង ឯរឿងនេះការចាប់ខ្លួនកូនក្តីរបស់ខ្លួនមានរយៈពេលរឿងហេតុរំលងជា២០ថ្ងៃ ទើបនគរបាលព្រហ្មទណ្ឌចុះចាប់ឃាត់ខ្លួនកូនក្តីខ្លួន ដែលស្ថិតនៅក្នុងផ្ទះទាំងអស់គ្នា។ វាផ្ទុយនឹងនីតិវិធីអនុវត្តព្រហ្មទណ្ឌអន្តរកាល។ ម្យ៉ាងទៀតការនោះ គឺនៅពេលយប់ ឯភ័ស្តុតាងគ្មានអ្វីទាំងអស់ យកចម្លើយតាមការធ្វើទារុណកម្មប៉ុណ្ណោះ បើពិនិត្យលើឈ្មោះ **ណណ** និងអ្នករងគ្រោះ ទើបមានទំនាក់ទំនងគ្នា។ ដោយឡែកឈ្មោះ **ណណ និង ណណ** គ្រាន់តែបងប្អូនគ្នាទេ ពុំមានទាក់ទិនការប្រព្រឹត្តបទល្មើសឡើយ។ សូមតុលាការកំពូល លើកលែងចោទប្រកាន់កូនក្តីរបស់ខ្លួន និងសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងស្រុង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងអយ្យការថា៖ពុំមានមតិអ្វីទៀតទេ។ សូមរក្សាសេចក្តីសន្និដ្ឋាន របស់ខ្លួនទៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ទាំងពីរនិងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើថា បណ្តឹងសាទុក្ខគ្មានលេខ ចុះថ្ងៃទី២៨-៤-០០ របស់ឈ្មោះ **ណណ និង ណណ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីតាំង និងសកម្មភាពរបស់សាលាជំនុំជម្រះក្តី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូច តុលាការខេត្តកណ្តាលដែរ ដែលសម្រេចផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ **ណណ និងឈ្មោះ ណណ** ដាក់ពន្ធនាគារដោយអាងហេតុថា មានពិរុទ្ធភាពគ្រប់គ្រាន់ពីបទមនុស្សឃាតគិតទុកជាមុន នោះពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ពីព្រោះថា៖

-ពុំមានភ័ស្តុតាងឯណា មួយបញ្ជាក់អំពីសកម្មភាព ធ្វើឃាតទៅលើជនរងគ្រោះឡើយ។

-ចម្លើយសាក្សីបំភ្លឺពុំមាន មូលដ្ឋានច្បាស់លាស់ឡើយពីព្រោះថាៈអំពើល្មើស កើតឡើងនៅពេលយប់ពីម៉ោង២០ទៅម៉ោង២១។

-វត្ថុតាងនៃអំពើល្មើស និងសំលៀកបំពាក់របស់ជនរងគ្រោះ ដែលសមត្ថកិច្ចដកហូតបាននៅក្បែរសពនិងលើខ្លួនសព ពុំស្របនឹងចម្លើយរបស់សាក្សីឡើយ។ សពជនរងគ្រោះរលេះរលួយនៅសល់តែលលាក្បាល ពុំមានភ័ស្តុតាងច្បាស់លាស់បញ្ជាក់ថា ជាសពរបស់ឈ្មោះ **វ** ដូចការអះអាងរបស់សាក្សីឡើយ។

-យល់ឃើញថាៈបទល្មើលមនុស្សឃាតនេះពុំមានលក្ខណៈជាបទល្មើស ជាក់ស្ដែងឡើយ ហើយតាមការចាប់ខ្លួន និងសួរចម្លើយជនជាប់ចោទ ធ្វើឡើង ដោយខុសនីតិវិធី។

-យល់ឃើញថា ដើម្បីឱ្យមានមូលដ្ឋានច្បាស់លាស់ តុលាការអង្គសេចក្ដី គប្បីធ្វើការស៊ើបអង្កេតបន្ថែមអំពីវត្តមានរបស់ជនជាប់ចោទ ពេលមានអំពើ មនុស្សឃាត និងទំនាក់ទំនងរបស់ជនជាប់ចោទជាមួយជនល្មើសដទៃទៀត ក៏ ដូចជាជនរងគ្រោះដែរ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងទាំង ទម្រង់ទាំងគតិច្បាប់។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្ដី ចំពោះមុខជនជប់ចោទ

១. ទទួលបណ្ដឹងសាទុក្ខគ្មានលេខចុះថ្ងៃទី២៨-៤-០០ របស់ឈ្មោះ **ណាណា និងណាណា** ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១០២ចុះថ្ងៃទី១៩-៤-០០ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ២០០ ០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែមី នា ឆ្នាំ២០០១។